ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ភ្នំពេញ ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៦

សេចក្តីប្រកាសព័ត៌មាន

អង្គជំនុំជម្រះសាលាដំបូងនឹងចាប់ផ្តើមសវនាការលើភ័ស្តុតាងនៅក្នុងប្រធានបទទីបួននៃសំណុំរឿង ០០២/០២ គឺ មន្ទីរសន្តិសុខ និង ការបោសសម្អាតផ្ទៃក្នុង

នៅថ្ងៃ ពុធ ទី ០២ ខែ មីនា ឆ្នាំ ២០១៦ អង្គជំនុំជម្រះសាលាដំបូង នឹងចាប់ផ្តើមសវនាការលើភ័ស្តុតាងក្នុងប្រធានបទទីបួននៃសំណុំរឿង ០០២/០២ គឺ មន្ទីរសន្តិសុខ និង ការបោសសម្អាតផ្ទៃក្នុង។ យោងតាមដីកាដំណោះស្រាយដែលចោទប្រកាន់លើ នួន ជា និង ខៀវ សំផន បក្សកុម្មុយនិស្តកម្ពុជាបានបំផ្លាញរចនាសម្ព័ន្ធច្បាប់ និងតុលាការរបស់ប្រទេសកម្ពុជា ហើយដាក់ជំនួសវិញនូវប្រព័ន្ធមន្ទីរសន្តិសុខ និង ទីកន្លែងសម្លាប់មនុស្ស ដើម្បីឃុំខ្លួនកសាង ឬ សម្លាប់ជនដែលជាប់សង្ស័យថាជាខ្មាំង។ នៅត្រឹមឆ្នាំ ១៩៧៩ មន្ទីរសន្តិសុខប្រហែល ២០០ កន្លែង និងទីកន្លែងសម្លាប់មនុស្សរាប់មិនអស់ត្រូវបានចោទថាបានបង្កើតឡើងនៅគ្រប់ភូមិភាគទូទាំងប្រទេសកម្ពុជា និង នៅតាមថ្នាក់ផ្សេងៗនៃរចនាសម្ព័ន្ធរដ្ឋបាល និង យោធារបស់បក្សកុម្មុយនិស្តកម្ពុជា។

ចាប់ពីថ្ងៃ ពុធ ទី ០២ ខែ មីនា ឆ្នាំ ២០១៦ តទៅ អង្គជំនុំជម្រះសាលាដំបូង នឹងធ្វើសវនាការដេញដោលលើភ័ស្តុតាងទាក់ទងនឹងមន្ទីរសន្តិសុខចំនួន ៣ កន្លែង គឺមន្ទីរសន្តិសុខអូរកន្សែងនៅខេត្តរតនៈគិរី មន្ទីរសន្តិសុខភ្នំក្រោលនៅខេត្តមណ្ឌលគិរី និង មន្ទីរសន្តិសុខ ស-២១ នៅភ្នំពេញ។ សវនាការនេះគឺជាសវនាការបន្តែមលើមន្ទីរសន្តិសុខ ៣ កន្លែងផ្សេងទៀតដែលអង្គជំនុំជម្រះបានធ្វើសវនាការរួចហើយនៅក្នុងសំណុំរឿង ០០២/០២ គឺមន្ទីរសន្តិសុខក្រាំង-តាចាន់នៅខេត្តតាកែវ មន្ទីរសន្តិសុខវត្តអូរត្រក្កួននៅភូមិភាគកណ្តាល និង មន្ទីរសន្តិសុខភូមិទ្រានៅភូមិភាគបូព៌ា។

អង្គជំនុំជម្រះសាលាដំបូង បានស្តាប់សក្ខីកម្មសាក្សីចំនួន ៦៨ រូប ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៣៧ រូប និងអ្នកជំនាញចំនួន ០២ រូប សម្រាប់សវនាការចំនួន ១៥០ ថ្ងៃ។ បន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងបញ្ចប់សវនាការស្តីពីមន្ទីរសន្តិសុខ និង ការបោសសម្អាតផ្ទៃក្នុងរួចហើយ ប្រធានបទបន្ទាប់ (ប្រធានបទទីប្រាំ) នៃសវនាការគឺពាក់ព័ន្ធនឹងការចោទប្រកាន់អំពីការរៀបការដោយបង្ខំនៅក្រោមរបបខ្មែរក្រហម។ បន្ទាប់ពីប្រធានបទនេះ អង្គជំនុំជម្រះសាលាដំបូងនឹងធ្វើសវនាការលើភ័ស្តុតាងស្តីពីជម្លោះប្រដាប់អាវុធរវាងប្រទេសកម្ពុជាជាមួយនឹងប្រទេសវៀតណាម

ហើយចុងក្រោយបំផុត នឹងងាកមកផ្តោតលើតួនាទីរបស់ ន្លួន ជា និង ខៀវ សំផន។ អង្គជំនុំជម្រះវិពីងថា សវនាការលើភ័ស្តុតាងនឹងបញ្ចប់នៅចុងឆ្នាំនេះ ហើយសាលក្រមនឹងប្រកាសនៅក្នុងឆ្នាំ ២០១៧។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

លោក ឡាស អូលសិន
មន្ត្រីទំនាក់ទំនងផ្នែកច្បាប់
ទូរសព្ទដៃលេខ៖ +៨៥៥ (០)១២ ៤៨៨ ០២៣
ទូរសព្ទលើតុលេខ៖ +៨៥៥ (០)២៣ ៨៦១ ៦៦៩
សារអេឡិចត្រូនិក: olsenl@un.org

លោក នេត្រ ភក្ត្រា
មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរសព្ទដៃលេខ៖ +៨៥៥ (០)១២ ៤៨៨ ១៥៦
ទូរសព្ទលើតុលេខ៖ +៨៥៥ (០)២៣ ៨៦១ ៥៦៤
សារអេឡិចត្រូនិក: neth.pheaktra@eccc.gov.kh